# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជានៅគខនយ
# ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៨
## *ស្រឡាញ់ព្រះជាម្ចាស់គឺប្រត្តិបត្តិតាមវិន័យរបស់ព្រះជាម្ចាស់*

អត្ថបទទី១៖ កក ៤,៣២-៣៥
អត្ថបទទី២៖ ១យហ ៥,១-៦
ដំណឹងល្អ៖ យហ ២០,១៩-៣១

បងប្អូនជាទីស្រឡាញ់!

ប៉ុន្មានឆ្នាំមុន ខ្ញុំទៅទីក្រុងយេរូសាឡឹមនៅផ្នូររបស់ព្រះយេស៊ូ គឺមានតែផ្នូរទទេរ។ បីថ្ងៃក្រោយពីព្រះយេស៊ូសោយទិវង្គត ព្រឹកឡើងនៅពេលស្ត្រីៗទៅដល់ផ្នូររបស់ព្រះយេស៊ូ គឺឃើញតែក្រណាត់សដែលគេបានរុំសពព្រះយេស៊ូ ប៉ុន្តែសពរបស់ព្រះអង្គអត់ឃើញទេ។ សព្វថ្ងៃផ្នូររបស់ព្រះយេស៊ូនៅក្នុងព្រះវិហារមួយ គ្រីស្តបរិស័ទគ្រប់និកាយគេថានេះជាផ្នូររបស់ព្រះយេស៊ូតាមជំនឿរបស់គេរៀងៗខ្លួន ដូច្នេះនៅជុំវិញផ្នូររបស់ព្រះយេស៊ូគេដាក់អាសនៈនិកាយគ្រីស្តសាសនាទាំងអស់។ គេមានម៉ោងដើម្បីអធិដ្ឋាន ជូនកាលត្រូវម៉ោងដូចគ្នាណែនាំឲ្យគ្រប់និកាយគេស្មូត គេច្រៀង គេអធិដ្ឋានតាមជំនឿរបស់គេរៀងៗខ្លួន។

សព្វថ្ងៃផ្នូររបស់ព្រះយេស៊ូមានតែថ្មមួយនៅទទេរ ថ្មនេះជាតំណាងថាព្រះយេស៊ូបានគង់នៅនៅពេលព្រះយេស៊ូស្លាប់។ ថ្ងៃនេះព្រះយេស៊ូបានបង្ហាញខ្លួន នៅពេលកំពុងហូបបាយជាមួយក្រុមគ្រីស្តទូត ដំបូងគ្រីស្តទូតគេភ័យគេខ្លាច ប៉ុន្តែក្រោយមកគេយល់ថា ព្រះយេស៊ូមិនមែនខ្មោច។ ជួនកាលព្រះយេស៊ូបង្ហាញខ្លួន នៅពេលក្រុមគ្រីស្តទូតគេកំពុងនេសាទព្រះយេស៊ូបានឲ្យគេទម្លាក់អួនទៅក្នុងទឹក ក្រោយមកគេបានត្រីច្រើនណាស់។ ថ្ងៃនេះឃើញព្រះយេស៊ូម្តងទៀត គ្រប់ពេលវេលាដែលព្រះយេស៊ូបានបង្ហាញខ្លួនព្រះអង្គមានព្រះបន្ទូលតែមួយគឺ "**សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខសាន្ត**" គ្រប់ពេលវេលាដែលព្រះយេស៊ូបង្ហាញខ្លួន ព្រះអង្គចង់ឲ្យក្រុមគ្រីស្តទូតមានសេចក្តីសុខសាន្ត។ ថ្ងៃនេះពិសេស ដោយសារព្រះយេស៊ូបានបង្ហាញរបួសនៅកន្លែងដែលគេឆ្កាងព្រះយេស៊ូ នៅដៃនៅជើង និងនៅទ្រូងដែលទាហានបានយកលំពែងមកចាក់ទម្លុះ ដើម្បីឲ្យប្រាកដថាព្រះយេស៊ូស្លាប់ឬនៅ។ នៅពេលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញរបួសនៅដដែល ដូច្នេះព្រះយេស៊ូបានបង្ហាញលោកតូម៉ាស ដែលមិនព្រមជឿថាព្រះអង្គមានព្រះជន្មរស់ឡើងវិញដោយឲ្យលោកតូម៉ាសដាក់ម្រាមដៃចូលទៅក្នុងស្នាមរបួសទាំងនោះ។ ព្រះយេស៊ូមានព្រះ

បន្ទូលថា "**អ្នកជឿមកពីអ្នកបានឃើញ អ្នកណាជឿដោយឥតបានឃើញសោះអ្នកនោះមានសុខភមង្គលហើយ**"។ ហេតុនេះហើយ យើងទាំងអស់គ្នាដែលនៅទីនេះយើងពោរពេញដោយសុភមង្គលដោយសារ យើងជឿលើព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ ដោយមិនបានឃើញអ្វីសោះ។ ថ្ងៃនេះយើងមានព្រះយេស៊ូគង់នៅជាមួយយើង យើងមើលមិនឃើញប៉ុន្តែយើងដឹងថាព្រះយេស៊ូគង់ជាមួយយើង ជាពិសេសតាមរយៈទូព្រះកាយដែលមានពន្លឺមួយណែនាំឲ្យយើងនឹកឃើញព្រះយេស៊ូគង់នៅជានិច្ច។ ព្រះយេស៊ូណែនាំឲ្យយើងរស់នៅជាគ្រីស្តបរិស័ទ ជាសាវ័ករបស់ព្រះយេស៊ូពោរពេញដោយសុភមង្គល។ នៅក្នុងអត្ថបទទីពីរ "**អ្នកជឿថាព្រះយេស៊ូពិតជាព្រះគ្រីស្ត អ្នកនោះកើតមកពីព្រះជាម្ចាស់ អ្នកណាស្រឡាញ់ព្រះបិតា អ្នកនោះក៏ស្រឡាញ់អ្នកដែលព្រះបិតាចាត់ឲ្យមកនោះដែរ**" ដោយយើងស្រឡាញ់ព្រះជាម្ចាស់និងអនុវត្តតាមវិន័យរបស់ព្រះអង្គ យើងដឹងថាយើងពិតជាស្រឡាញ់បុត្រធីតារបស់ព្រះជាម្ចាស់។ សម្រាប់យើង ដែលចង់ដើរតាមព្រះយេស៊ូដែលមានព្រះជន្មរស់នៅសព្វថ្ងៃយើងត្រូវតែ **ស្រឡាញ់ព្រះជាម្ចាស់ ប្រត្តិបត្តិតាមវិន័យរបស់ព្រះជាម្ចាស់** គឺស្រឡាញ់គ្នាទៅវិញទៅមកដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ។ គ្រីស្តបរិស័ទពីដើម គេរស់នៅដោយចេះជួយគ្នាទៅវិញទៅមក "**នៅក្នុងចំណោមគ្រីស្តបរិស័ទ គ្មាននរណាខ្វះខាតអ្វីឡើយ អស់អ្នកដែលមានដីធ្លីឬផ្ទះសម្បែងនាំគ្នាលក់ដីនិងផ្ទះសម្បែងនោះ យកប្រាក់មកជួយគ្រីស្តបរិស័ទ បន្ទាប់មកអ្នកជឿទាំងអស់គ្នាទទួលចំណែកតាមសេចក្ដីត្រូវការរៀងៗខ្លួន**" ពីសម័យដើមអ្នកដែលមានជួយអ្នកដែលក្រ ដើម្បីអនុវត្តវិន័យរបស់ព្រះយេស៊ូ យើងជាបងប្អូន យើងជាគ្រួសារតែមួយ យើងចេះស្រឡាញ់គ្នាទៅវិញទៅមក។ នៅក្នុងក្រុមគ្រួសារមួយនៅពេលយើងមានបងប្អូនយើងណាម្នាក់ដែលមានបញ្ហាខ្វះខាត យើងយកចិត្តទុកដាក់ជួយគេ សម្រាប់គ្រួសារយើងជាគ្រីស្តបរិស័ទក៏ដូចគ្នាដែរ យើងធ្វើដូចម្ដេចដើម្បីជួយគ្នា? យើងធ្វើដូចម្ដេចដើម្បីលើកទឹកចិត្តគ្នា? នៅពេលយើងឃើញមានបងប្អូនណាម្នាក់ដែលឈឺយើងណែនាំឲ្យគាត់ទៅមន្ទីរពេទ្យ នៅពេលយើងឃើញបងប្អូនខ្វះខាតយើងជួយសម្រុះសម្រួលខ្លះៗឲ្យគាត់។ យើងជាគ្រីស្តបរិស័ទ យើងមិនមែនមានតែគ្រួសារផ្ទាល់ខ្លួនរបស់យើង ប៉ុន្តែព្រះសហគមន៍ក៏ជាក្រុមគ្រួសាររបស់យើងដែរ។

ជាពិសេសនៅក្នុងឆ្នាំនៃគ្រួសារ យើងទាំងអស់គ្នាគិតធ្វើដូចម្ដេចដើម្បីឲ្យក្រុមគ្រួសាររបស់យើងប្រសើរឡើងៗ? នៅក្នុងគម្ពីរ "**ព្រះយេស៊ូណែនាំឲ្យយើងមានជីវិត ព្រះយេស៊ូ**

**ណែនាំឲ្យយើងមានសេចក្ដីសុខ ព្រះយេស៊ូណែនាំឲ្យយើងចេះលើកលែងទោសទៅវិញទៅមក និងព្រះយេស៊ូណែនាំឲ្យយើងចេះបង្កើតក្រុមបងប្អូនដែលចេះលើកទឹកចិត្តគ្នា ចេះជួយគ្នាទៅវិញទៅមក ដូចគ្រីស្ដបរិស័ទ២០០០ឆ្នាំមុន**"។ យើងធ្វើដូចម្ដេច ដើម្បីឲ្យយុវជនយុវនារីដែលមិនមែនជាគ្រីស្ដបរិស័ទយល់ថា កន្លែងរបស់យើងជាគ្រួសារមួយយ៉ាងពិសេស គ្រួសាររបស់ព្រះយេស៊ូ គ្រួសាររបស់បងប្អូនដោយជឿថាព្រះយេស៊ូគង់នៅជាមួយយើង។ ដូច្នេះយើងអរព្រះគុណព្រះជាម្ចាស់ ដោយបន្តអធិដ្ឋានដើម្បីឲ្យក្រុមគ្រួសារនៅក្នុងព្រះសហគមន៍ ទៅជាគ្រួសារដែលណែនាំឲ្យយើងទាំងអស់គ្នារស់នៅដូចគ្រីស្ដបរិស័ទពីដើម ដោយចេះជួយគ្នាទៅវិញទៅមក ចេះស្រឡាញ់គ្នាទៅវិញទៅមក ដោយស្រឡាញ់ព្រះជាម្ចាស់ជានិច្ច។ អាម៉ែន